ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លេខ ០៨៦៤.សសរ..... គ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី.០៤....ខែ..មិថុនា..ឆ្នាំ២០០៩

# សេចក្តីសម្រេច

## ស្តីពី

## ការស៊ើបអង្កេត និងការដោះស្រាយពាក្យបណ្តឹងរបស់ក្រុមការងារគណនេយ្យភាព រាជធានី ខេត្ត

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

– បានឃើញសេចក្តីសម្រេចលេខ ០១២ ស.ស.រ/គ.ជ.វ.រ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារគណនេយ្យភាពជាតិ

– បានឃើញសេចក្តីណែនាំលេខ ០១៤ ស.ណ.ន/គ.ជ.វ.រ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង។

## សម្រេច

### ប្រការ ១.-

ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត មានសមត្ថកិច្ចពិនិត្យ និងដោះស្រាយពាក្យបណ្តឹងទាំងអស់ដែលពាក់ព័ន្ធនឹង:

ក. ការប្រើប្រាស់ថវិកាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ :

- ថវិកាគ្រប់ប្រភពទាំងអស់ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- ថវិកាទាំងឡាយណាដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ. អ.ប
- មូលនិធិឃុំ សង្កាត់ និងថវិកាផ្សេងទៀត ដែលស្ថិតនៅក្នុងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

ខ. ការអនុវត្តមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានកំណត់ដោយច្បាប់ស្តីពីការគប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតដែលស្របដោយច្បាប់ទាំង ២នេះ។

### ប្រការ ២.-

ក្នុងការដោះស្រាយពាក្យបណ្តឹង ដូចមានចែងក្នុងប្រការ ១ ខាងលើ ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវចាត់តាំងក្រុមស៊ើបអង្កេតក្នុងការស្វែងរកភាពពិតប្រាកដនៃអង្គហេតុ តាមរយៈការប្រមូលភស្តុតាង ដើម្បីជាមូលដ្ឋានសម្រាប់កិច្ចប្រជុំក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ពិនិត្យ និងសម្រេចដោះស្រាយពាក្យបណ្តឹង។

ក្រុមស៊ើបអង្កេតមានសិទ្ធិអំណាចដូចខាងក្រោម :

- ស្នើឯកសារជាលាយលក្ខណ៍អក្សរ
- ស្រាវជ្រាវរកឯកសារនៅកន្លែងធ្វើការជនត្រូវចោទ
- សម្ភាសន៍ជាមួយដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ
- ចុះពិនិត្យកន្លែងកើតហេតុ

– ពិគ្រោះយោបល់ជាមួយអ្នកជំនាញ

– ស្នើសុំអន្តរាគមន៍ពីអភិបាលរាជធានី ខេត្ត ក្នុងករណីមានការគំរាមគំហែងដល់សុវត្ថិភាពរបស់ក្រុមស៊ើបអង្កេត ។

អ្នកស៊ើបអង្កេតមិនអាចធ្វើការឆែកឆេរផ្ទះសម្បែង ការិយាល័យ និងគណនីធនាគារផ្ទាល់ខ្លួនរបស់ជនត្រូវចោទ ។

**ប្រការ ៣.–**

ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវអនុវត្តនីតិវិធីដែលបានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ ដើម្បីធ្វើការដោះស្រាយពាក្យបណ្តឹង ។

**ប្រការ ៤.–**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ត្រូវតាមដាន និងជំរុញដំណើរការអនុវត្តរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ។

ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត នៅរាល់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្តអំពីដំណើរការការងាររបស់ខ្លួន ។

**ប្រការ ៥.–**

រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នសមាជិកគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមការងារគណនេយ្យភាពជាតិ ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្ត សេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជ. គណៈកម្មាធិការជាតិសម្រាប់**
**ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**ប្រធាន**

**ស ខេង**

***ចម្លងជូន***
-ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប
" ដើម្បីសហការអនុវត្ត"
-ក្រុមការងារគណនេយ្យភាពរាជធានី ខេត្តទាំងអស់
" ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ